ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
គណៈកម្មការរៀបចំការប្រឡង

# សេចក្តីជូនដំណឹង
# ស្តីពី
# ការធ្វើនិយ័តក្របខណ្ឌក្នុងការប្រឡងប្រជែងជ្រើសរើសបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០១៩

**យោង ៖**
- លិខិតលេខ១០៩៧ មស.ក្រខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- ប្រកាសលេខ៣១៤១ មស.ប្រក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- លិខិតលេខ៣៣៣៦ មស.សជណ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- របាយការណ៍ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ការប្រជុំស្តីពី ការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌ សម្រាប់ឆ្នាំ ២០១៩ ក្រសួងស្ថាប័នទាំង០៤
- របាយការណ៍ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ការប្រជុំស្តីពី ការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌ សម្រាប់ឆ្នាំ ២០១៩ ក្រសួងស្ថាប័នទាំង០៤
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

គណៈកម្មការរៀបចំការប្រឡង សូមជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ទាំងអស់ឱ្យបានជ្រាបថា ដោយពិនិត្យឃើញថា ប៉ុស្តិ៍ដែលប្រកាសជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុង **សេចក្តីជូនដំណឹង លេខ ៣៣៣៦ មស.សជណ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ** ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចំពោះបេក្ខជនដែលបានពិន្ទុទាបជាងមធ្យមភាគដែលបានកំណត់ គណៈកម្មការរៀបចំការប្រឡងសុំធ្វើការនិយ័តកន្លែងដែលបេក្ខជនមានពិន្ទុក្រោមមធ្យមភាគ ជូនទៅកន្លែងដែលបេក្ខជនមានពិន្ទុជាប់មធ្យមភាគដូចខាងក្រោម៖

1) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍រដ្ឋបាលជលផលចំនួន ០១ កន្លែង ជូននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
2) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍រដ្ឋបាលព្រៃឈើចំនួន ០២ កន្លែង ជូននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
3) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍អគ្គនាយកដ្ឋានកៅស៊ូចំនួន ០១ កន្លែង ជូននាយកដ្ឋានផែនការស្ថិតិ
4) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន ០២ កន្លែង ជូនអគ្គនាយដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
5) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍សាលាជាតិកសិកម្មកំពង់ចាមចំនួន ០១ កន្លែង ជូននាយកដ្ឋានបុគ្គលិក និង អភិវឌ្ឍន៍ធនធានមនុស្ស
6) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវចំនួន ០១ កន្លែង ជូននាយកដ្ឋាននីតិកម្មកសិកម្ម

7) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យចំនួន ០១ កន្លែង និងប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាបចំនួន ០២ កន្លែង ជូននាយកដ្ឋានកសិ.ឧស្សាហកម្ម

8) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំចំនួន ០២ កន្លែង និងប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំចំនួន ០១ កន្លែង ជូនសាលកវិទ្យាល័យភូមិន្ទកសិកម្ម

9) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះចំនួន ០២ កន្លែង និងប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តរតនគីរីចំនួន ០១ កន្លែង ជូននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

10) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែងចំនួន ០១ កន្លែង ជូនមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

11) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្វាយរៀងចំនួន ០១ កន្លែង ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្តាល

12) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគីរីចំនួន ០២ កន្លែង ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពតចំនួន ០១ កន្លែង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកែបចំនួន ០១ កន្លែង

13) ត្រូវបាននិយ័តក្របខណ្ឌប៉ុស្តិ៍មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបងចំនួន ០២ កន្លែង ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំងចំនួន ០១ កន្លែង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺចំនួន ០១ កន្លែង។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមបេក្ខជនសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ទាំងអស់ដែលបានដាក់ពាក្យប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌក្រសួង ស្ថាប័នទាំង៤ ខាងលើជ្រាបជាព័ត៌មាន៕

ថ្ងៃ សុក្រ ៤រោច ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋលេខាធិការនិងជា**
**ប្រធានគណៈកម្មការរៀបចំការប្រឡង**

ខៀវ ច័ន្ទប៊ុនធឿន

**ចម្លងជូន៖**
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
" ដើម្បីសហការអនុវត្ត និងជួយផ្សព្វផ្សាយ "
-ឯកសារ កាលប្បវត្តិ